ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាលដីកា
តាមនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

សំណុំព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៣៨
ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩
សាលដីកា
លេខ ២៩ "II"
ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

ក្រឡាបញ្ជីសវនាការ

លោក [redacted]

តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ឋានៈជាអគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៣១ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៨៨ ក្រV "ប.ស" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ដែលមាន ៖

-បុគ្គលប្តឹងសាទុក្ខ ៖ ជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត ភេទប្រុស អាយុ ៣១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ជាងឡាន ទីកន្លែងកំណើតនៅភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទីលំនៅមុនពេលចាប់ខ្លួននៅផ្ទះ [redacted] ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

- ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤០៧ ត.ព្រ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ ។



Scanned with CamScanner

- មានលោក [redacted] ផានិត ជាមេធាវីការពារ។

-ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ផ្លូវលំ ក្រុមទី៣ ភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## អំពីអង្គហេតុ

កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ វេលាម៉ោង ១០ និង៣០នាទី កម្លាំងសមត្ថកិច្ចនៃការិយាល័យប្រឆាំងគ្រឿងញៀន បានចុះពិនិត្យ និងធ្វើការឆែកឆេរ នៅចំណុចផ្ទះគ្មានលេខ ផ្លូវលំ ក្រុមទី៣ ភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ រកឃើញវត្ថុតាងរួមមាន ក្រាមពណ៌សថ្លាចំនួន ៥កញ្ចប់ធំ ឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនចំនួន ០១ ដែកកេះដ៏ចំនួន ០២ ប្រាក់រៀលចំនួន ៨២.១០០៛ ប្រាក់ដុល្លារចំនួន ២០$ ឧបករណ៍សម្រាប់ចូកគ្រឿងញៀនចំនួន ០២ និងកូនកន្ត្រៃសម្រាប់ច្រិបដែកតូចចំនួន ០១ ព្រមទាំងបានចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត។ សមត្ថកិច្ចបានសាកសួរជនជាប់ចោទរូបនេះ បានទទួលលទ្ធផលថា ក្រាមពណ៌សថ្លានេះ ខ្លួនបានទិញពីឈ្មោះ ចន ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ ក្នុងតម្លៃ ៣.២០០$ ក្នុងមួយខាំ ហើយយកមកវែលកជាកញ្ចប់តូចៗដើម្បីលក់ឱ្យម៉ូយបន្ត។ មន្ត្រីជំនាញនៃការិយាល័យប្រឆាំងគ្រឿងញៀន បានយកក្រាមពណ៌សថ្លាមកធ្វើតេស្តជំហានដំបូងជាមួយប្រភេទម៉ាគីតេស្ត (Marquis Test) ជាលទ្ធផលបង្ហាញឱ្យឃើញថា ក្រាមពណ៌សថ្លា ចេញពណ៌លឿងទុំ មានសារធាតុញៀនប្រភេទមេតំហ្វេតាមីន ។ សមត្ថកិច្ចធ្វើការឃាត់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត និងដកហូតវត្ថុតាង រួចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធីច្បាប់ ។

សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៤០០ ក្រ៤ "ផ" ក.ព.ព្រ.ទ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅនេះ ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់) ឆ្នាំ ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ផ្លូវលំ ក្រុមទី៣ ភូមិគោកឃ្លាំង សង្កាត់ភ្នំពេញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ វេលាម៉ោង ១០ និង ៣០នាទី តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុតាងដែលចាប់យកមាន៖

ក. គ្រឿងញៀនប្រភេទម្សៅទម្ងន់សរុប ២០៥,៩ក្រាម គុណនឹង ៦៩,៤៨ ចែកនឹង ១០០មានភាពសុទ្ធស្មើនឹង ១៤៣,១០១ក្រាម (មួយរយសែសិបបីក្បៀសមួយរយមួយក្រាម) ។

- ជញ្ជីងថ្លឹងគ្រឿងញៀនចំនួនមួយ (ចាស់) ។



Scanned with CamScanner

- ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន និងដែកកេះចំនួនពីរ ។

- ឧបករណ៍សម្រាប់ដក់គ្រឿងញៀនចំនួនពីរ និងកន្ត្រៃច្រិបពណ៌ក្រហមមួយ ។

ត្រូវរឹបអូសតាមបញ្ញត្តិមាត្រា ៩៣, ៩៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ. ប្រាក់រៀលចំនួន ៨២១០០រៀល (ប្រាំបីម៉ឺនពីរពាន់មួយរយរៀល) និងប្រាក់ដុល្លារ ២២ ដុល្លារអាមេរិក ។

- ទូរស័ព្ទដៃចំនួនបីគ្រឿងមានម៉ាក SAMSUNG G900W មួយគ្រឿង ពណ៌ខ្មៅ (ចាស់), ម៉ាក NOKIAចុចពិល ពណ៌ខ្មៅ (គ្មានគម្របក្រោយចាស់) មួយគ្រឿង និងម៉ាក One touch ពណ៌ផ្កាឈូក មួយគ្រឿង (ចាស់) ។

ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

- សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ ។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

សាលក្រមនេះត្រូវបានជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត ប្ដឹងឧទ្ធរណ៍ តាមបណ្ដឹងលេខ ៧៣៦ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ ត្រង់ចំណុចទាំងមូលនៃសាលក្រម។

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៨៨ ក្រV "ប.ស" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១. ទទួលបណ្ដឹងឧទ្ធរណ៍លេខៈ ៧៥៦ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២. តម្កល់សាលក្រមលេខ ៤០០ក្រ៤ "ផ"កពព្រ/ទ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣. បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

- សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត ប្រកាសជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ។

- បើកសិទ្ធិប្ដឹងតវ៉ា តាមកំណត់ច្បាប់ ។

សាលដីកានេះ ត្រូវបានជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត ប្ដឹងសាទុក្ខ តាមបណ្ដឹងលេខ ៣៣១ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូលនៃសាលដីកា។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍



Scanned with CamScanner

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្តីសន្និដ្ឋានថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត គឺមិនមែនមូលហេតុដូចក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យតុលាការកំពូលបដិសេធសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ឡើយ។ ហេតុដូច្នេះតំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ ទទួលបណ្តឹងសាទុក្ខលេខ ៣៣១ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ផ្ទុយនឹងគតិច្បាប់ និងតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៨៨ ក្រV "ប.ស" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត បានឆ្លើយថាខ្លួនគ្រាន់តែតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនប៉ុណ្ណោះ ពីព្រោះបានឆ្លើយសារភាពអស់ហើយ។

-លោកមេធាវី [redacted] ផានិត បានធ្វើសេចក្តីសន្និដ្ឋានថា រឿងនេះជនជាប់ចោទសារភាព ហើយមានភស្តុតាងស៊ីចង្វាក់គ្រប់គ្រាន់ ប៉ុន្តែអ្វីដែលខ្លួនសុំគឺសុំឱ្យតុលាការកំពូលពិចារណាលើបណ្តឹងសាទុក្ខក្នុងគោលបំណងធំ គឺសុំបន្ធូរបន្ថយទោសតែប៉ុណ្ណោះ។ បើយោងទៅតាមក្រមព្រហ្មទណ្ឌ ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ "កាលៈទេសៈនៃបទល្មើស" ថាតើជនជាប់ចោទនោះប្រព្រឹត្តបទល្មើសគឺគ្រាន់តែដើម្បីរស់ ឬក៏ដើម្បីមានបាន ចំណុចនេះ សាលាដំបូងក៏ដូចជាសាលាឧទ្ធរណ៍ មិនបានលើកយកមកពិចារណានោះទេ។ ហេតុដូច្នេះក្នុងខ្លួនជាមេធាវីការពារឱ្យជនជាប់ចោទ ខ្លួនសុំឱ្យក្រុមប្រឹក្សា ក៏ដូចជាឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាទៅលើចំណុចស្ថានសម្រាលទោសដល់ជនជាប់ចោទផង។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៣១ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] វណ្ណនិត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទបានអះអាងថា រឿងរ៉ាវកន្លងមក កូនក្តីរបស់ខ្លួនបានទទួលស្គាល់នូវកំហុសអំពីការប្រព្រឹត្តបទល្មើសតាមការចោទប្រកាន់ហើយ។ ប៉ុន្តែ មូលហេតុ ដែលកូនក្តីរបស់ខ្លួនមិនសុខចិត្ត និងបានប្តឹងសាទុក្ខនឹងសាលដីការបស់សាលាឧទ្ធរណ៍នេះ



Scanned with CamScanner

គោលបំណងគឺ ដើម្បីសុំតុលាការកំពូលបន្ធូរបន្ថយទោសបន្ថែមទៀតនោះ តុលាការកំពូលពិចារណាថា សវនាការនៅចំពោះមុខតុលាការកំពូលនៅដំណាក់កាលទទួលពិនិត្យលើបណ្ដឹងសាទុក្ខលើកទី១ នេះ តុលាការកំពូលមានសមត្ថកិច្ចពិនិត្យ ពិចារណា វិនិច្ឆ័យ តែទៅលើផ្នែកអង្គច្បាប់នៃបណ្ដឹងសាទុក្ខ និងសាលដីកាដែលទទួលរងការប្ដឹងសាទុក្ខតែប៉ុណ្ណោះ ផ្អែកតាម បទប្បញ្ញត្តិមាត្រា៤១៩ (មូលហេតុនៃបណ្ដឹងសាទុក្ខ),មាត្រា ៤៣៦ (សេចក្ដីសម្រេចលើបញ្ហាគតិយុត្ត) និងមាត្រា ពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ឯពាក់ព័ន្ធនឹងការបន្ធូរបន្ថយទោស គឺជាសមត្ថកិច្ចរបស់តុលាការអង្គហេតុ។

ម៉្យាងវិញទៀត សេចក្ដីសម្រេចអំពីទោស និងប្រកាសទោសដាក់ពន្ធនាគារកំណត់ត្រឹមតែ ១០ (ដប់) ឆ្នាំ ផ្អែកតាមបទប្បញ្ញត្តិមាត្រា ៤០ (កថាខណ្ឌទី៦ ចំណុចទី៤) ដែលទម្ងន់សារធាតុញៀនសុទ្ធជាប្រភេទមេតំហ្វេតាមីន មានទម្ងន់រហូតដល់ ១៤៣,១០១ ក្រាមឯណោះ ដែលបទប្បញ្ញត្តិមាត្រា ៤០ (កថាខណ្ឌទី៦ ចំណុចទី៤) បញ្ញត្តថា " កាលបើកម្រិតបរិមាណសារធាតុញៀនសុទ្ធជាប្រភេទអំហ្វេតាមីន ឬមេតំហ្វេតាមីន ឬ អ៊ិចស្តាស៊ី មានទម្ងន់ចាប់ ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ ២៤០ (ពីររយសែសិប) ក្រាម ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារចាប់ពី ១០ (ដប់) ឆ្នាំ រហូតដល់ ២០ (ម្ភៃ) ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ចាប់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល រហូតដល់ ៤០.០០០.០០០ (សែសិប) លានរៀលឯណោះ។ ដូច្នេះបើប្រៀបធៀបទៅនឹងកម្រិតទោសដែលតុលាការអង្គសេចក្ដី បានសម្រេច និងប្រកាសទោសចំពោះជនជាប់ចោទនេះ ពិតជាស្ថិតក្នុងកម្រិតអប្បបរមាហើយ។

ម៉្យាងទៀតតុលាការកំពូលកត់សម្គាល់ឃើញថា តុលាការអង្គហេតុផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted]វណ្ណនិត ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយយោងត្រឹមតែតាមបទប្បញ្ញត្តិមាត្រា ៤០ នៃច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀននោះ មិនទាន់ត្រឹមត្រូវពេញលេញនោះទេ ដែលគប្បីត្រូវថែមនូវ *"កថាខណ្ឌទី៦ ចំណុចទី៤"* ក្នុងកថាខណ្ឌទី២ នៃសេចក្ដីសម្រេចទី១ នៃសាលក្រមព្រហ្មទណ្ឌលេខ ៤០០ ក្រ៤ "ផ" ក.ព.ព្រ.ទ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ ដើម្បីឱ្យសមស្របទៅតាមកម្រិតសុទ្ធនៃសារធាតុញៀនដែលជាវត្ថុតាងនៃអង្គហេតុចោទប្រកាន់នេះទៀត ទើបត្រឹមត្រូវច្បាស់លាស់ ពីព្រោះថាក្នុងបទប្បញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន បញ្ញត្តិមានច្រើនកថាខណ្ឌ ហើយកថាខណ្ឌនីមួយៗ មានខ្លឹមសារ និងកម្រិតទោសខុសៗគ្នា ។

តុលាការកំពូលក៏កត់សម្គាល់ឃើញផងដែរថា តុលាការអង្គហេតុមិនបានអនុវត្តច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនដែលជាច្បាប់សារធាតុឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃបទប្បញ្ញត្តិមាត្រា ២៧ និងមាត្រា ២៨ នៃច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងបទប្បញ្ញត្តិ ៦៦៨ នៃក្រមព្រហ្មទណ្ឌនោះឡើយ ។ ពីព្រោះច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿង គឺជាបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌមានចរិតពិសេស។ ការអនុវត្តបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌមានចរិតពិសេស តុលាការមិនត្រូវអនុវត្តដោយយោងតាមខ្លឹមសារបទប្បញ្ញត្តិត្រង់កថាខណ្ឌទី២ នៃមាត្រា ៦៦៨ និងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌនោះទេ ។ ក្នុងរឿងក្ដីនេះ តុលាការអង្គហេតុមិនបានអនុវត្តការផ្ដន្ទាទោសពិន័យជាប្រាក់លើ ជនជាប់ចោទ នេះគឺជាកំហុស ។ ក៏ប៉ុន្តែ ដោយហេតុថាតុលាការ



Scanned with CamScanner

កំពូលនាពេលនេះ សម្រេចតែទៅលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ដូច្នេះតុលាការកំពូលមិនអាចសម្រេចបន្ថែមទម្ងន់ទោសទៅលើជនជាប់ចោទបានឡើយ ។

៣-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងអះអាងថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនិត គ្មានមូលហេតុបណ្តឹងសាទុក្ខតាមបញ្ញត្តិច្បាប់ទេ ហេតុដូចនេះ សុំឱ្យតុលាការកំពូលពិចារណាទៅតាមទិដ្ឋភាពច្បាប់។ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល ដូចនេះមានខ្លឹមសារដូចការដែលតុលាការកំពូលបានលើកយកមកពិនិត្យពិចារណា វិនិច្ឆ័យ ដូចមានក្នុងសំអាងហេតុត្រង់ចំណុចទី២ ខាងលើនេះរួចហើយ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៨៨ ក្រV "ប.ស" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមគតិច្បាប់។

**ហេតុដូច្នេះ**

**សម្រេចសេចក្តី**

១-បដិសេធបណ្តឹងសាទុក្ខលេខ ៣៣១ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] វណ្ណនិត ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៨៨ ក្រV "ប.ស" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល ។

*សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី៣១ ខែមករា ឆ្នាំ២០២០ និងប្រកាសសាលដីកាជាសាធារណៈ នៅថ្ងៃសុក្រ ទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ ។*

Scanned with CamScanner